# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

រាជធានីភ្នំពេញ, ថ្ងៃទី..១៤..ខែ..ធ្នូ..ឆ្នាំ ២០១៣

លេខ:..៤៧៤..វប.វស..

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការកណ្តាល អនុគណៈកម្មការ និងក្រុមការងារសន្និបាតបូកសរុបការងារ វប្បធម៌ និង វិចិត្រសិល្បៈឆ្នាំ២០១៣ និងលើកទិសដៅឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## សម្រេច

**ប្រការ១ ៖**

ត្រូវបានបង្កើតគណៈកម្មាធិការកណ្តាលមួយសម្រាប់គ្រប់គ្រង និងទទួលខុសត្រូវសន្និបាតបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៣ និងលើកទិសដៅឆ្នាំ២០១៤ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ នៅសាលសន្និសីទចតុម្មុខដែលមានសមាសភាពដូចខាងក្រោម ៖



ទូរស័ព្ទ / ទូរសា : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម | **ជុច គឿន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម | **ថៃ នរៈសត្យា** | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោកជំទាវ | **ម៉ិញ្ញ កុសលី** | រដ្ឋលេខាធិការ | សមាជិកា |
| ៥- ឯកឧត្តម | **អ៊ុក សុជាត** | រដ្ឋលេខាធិការ | សមាជិក |
| ៦- ឯកឧត្តម | **សោម សុគន្ធ** | រដ្ឋលេខាធិការ | សមាជិក |
| ៧- ឯកឧត្តម | **សំរាំង កំសាន្ត** | រដ្ឋលេខាធិការ | សមាជិក |
| ៨- លោកជំទាវ | **ធីង ស៊ីមន** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ៩- ឯកឧត្តម | **គង់ កន្ថារ៉ា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០- ឯកឧត្តម | **អ៊ុន ធឹម** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១- ឯកឧត្តម | **ស្រី សួន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២- ឯកឧត្តម | **ហ៊ី វរៈ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៣- លោកជំទាវ | **នេត្រ ភូម៉ារី** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ១៤- ឯកឧត្តម | **ចំរើន វ៉ាន់ថា** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥- ឯកឧត្តម | **ឡុង ប៉ុណ្ណាសិរីវត្ត** | អគ្គនាយកបច្ចេកទេស | សមាជិក |
| ១៦- ឯកឧត្តម | **ហាប់ ទូច** | អគ្គនាយកបេតិកភណ្ឌ | សមាជិក |
| ១៧- ឯកឧត្តម | **បុង សុវត្ត** | សាកលវិទ្យាធិការ | សមាជិក |
| ១៨- លោក | **អ៊ឹម គឹមលន** | អធិការនៃអធិការដ្ឋាន | សមាជិក |
| ១៩- លោក | **ឈឹម លាងសេង** | ប្រធាននា.សវនកម្មផ្ទៃក្នុង | សមាជិក |
| ២០- លោក | **យន យ៉យ** | នាយកសាលាមធ្យមវិចិត្រសិល្បៈ | សមាជិក |

គណៈកម្មការកណ្តាលនេះ មានភារកិច្ចៈ

- ទទួលខុសត្រូវរួមលើដំណើរការទូទៅនៃអង្គសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ឆ្នាំ២០១៣ និង លើកទិសដៅផែនការសកម្មភាពការងារវប្បធម៌ឆ្នាំ២០១៤ ។

**ប្រការ២ ៖**

ត្រូវបានបង្កើតអនុគណៈកម្មការលេខាធិការដ្ឋានមួយ ជាជំនួយដល់គណៈកម្មការកណ្តាលដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ចំរើន វ៉ាន់ថា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | **ព្រុំ សំអ៊ាន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- លោក | **ខន ខ្មែរជួ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- លោក | **ឡាយ សំអូន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក | **យិន់ អាន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៦- លោក | **សែន កុសល** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧- លោក | **ច័ន្ទ ចរណ្ណា** | ប្រធាននាយកដ្ឋានសម្ភារៈ និងបរិក្ខារ | សមាជិក |
| ៨- លោក | **មួច ច័ន្ទថាសនា** | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | សមាជិក |
| ៩- លោក | **ម៉ាន់ ចរៈ** | ប្រធាននា.គណនេយ្យនិងហិរញ្ញវត្ថុ | សមាជិក |
| ១០- លោកស្រី | **រស់ សារុ** | ប្រធាននា. សៀវភៅនិងការអាន | សមាជិកា |
| ១១- លោក | **ម៉ៅ គេច** | ប្រធាននា.សិល្បៈទស្សនីយ៍ភាព | សមាជិក |
| ១២- លោក | **ចឹម ពេញបុទ្ធ** | នាយខុទ្ទកាល័យ | សមាជិក |
| ១៣- លោកស្រី | **ស៊ឹម សុខហៀង** | អនុប្រធានការិយាល័យ | សមាជិកា |

អនុគណៈកម្មការនេះមានភារកិច្ចៈ

- រៀបចំលិខិតបទដ្ឋានរដ្ឋបាល កសាងឯកសារទាំងឡាយដែលពាក់ព័ន្ធជាមួយសន្និបាត និងរៀបចំសុន្ទរកថាជូនថ្នាក់ដឹកនាំ
- រៀបចំសណ្តាប់ធ្នាប់ ការពារសន្តិសុខ សុវត្ថិភាព អនាម័យ ពេទ្យ និងទំនាក់ទំនងជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដី
- រៀបចំគម្រោងស្នើសុំថវិកាពីរាជរដ្ឋាភិបាល
- គ្រប់គ្រងការចំណាយថវិកាសម្រាប់សន្និបាត និងធ្វើរបាយការណ៍បូកសរុបចំណូល ចំណាយ ជូនគណៈកម្មការកណ្តាល
- ផ្គត់ផ្គង់ភេសជ្ជៈ នំ ចំណី ផ្លែឈើក្នុងពិធីសន្និបាត
- បំពេញភារកិច្ចផ្សេងទៀតដែលគណៈកម្មការកណ្តាលប្រគល់ជូន។

**ប្រការ៣ៈ**

ត្រូវបានបង្កើតក្រុមការងាររៀបចំឯកសារ ជាជំនួយការឲ្យអនុគណៈកម្មការលេខាធិការដ្ឋានដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- លោក | **ប៉ែន សេរីឧត្ត** | ប្រធាននា.ផែនការស្ថិតិនិងសរុប | ប្រធាន |
| ២- លោក | **ប្រាក់ សុណ្ណារ៉ា** | អគ្គនាយករងបេតិកភណ្ឌ | អនុប្រធាន |
| ៣- លោក | **ដួង សាមុត** | អគ្គនាយករងបច្ចេកទេសវប្បធម៌ | អនុប្រធាន |

៤- លោក ខ៉ា ប៊ូរិន សាកលវិទ្យាធិការរង អនុប្រធាន

៥- លោក ហ៊ឹម និមល នាយកសាលាបណ្ដុះបណ្ដាល សមាជិក

៦- លោក កុក រស់ ប្រធាននា. នីតិកម្ម សមាជិក

៧- លោក អាំង ខុត្ដា អនុនា. ផែនការ ស្ថិតិ និងសរុប សមាជិក

៨- លោក ហ៊ិន រិទ្ធី ប្រធានការិ.នៃនា.ផែនការ ស្ថិតិនិងសរុប សមាជិក

៩- លោក ឡុង សំណាង ប្រធានការិ.នៃនា.ផែនការ ស្ថិតិនិងសរុប សមាជិក

ក្រុមការងារនេះមានភារកិច្ច ៖

- ប្រមូលឯកសារ របាយការណ៍សកម្មភាពពីគ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង និងពីមន្ទីររាជធានី/ខេត្ត ដើម្បីសម្របសម្រួលរៀបចំសេចក្ដីព្រាងបូកសរុបសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៣ និងលើកទិសដៅផែនការសកម្មភាពការងារឆ្នាំ២០១៤
- កត់ត្រាលទ្ធផលនៃការពិភាក្សានៅក្នុងអង្គសន្និបាតត្រៀម និងអង្គសន្និបាតពេញអង្គ បូកសរុបសកម្មភាពការងារវប្បធម៌និងវិចិត្រសិល្បៈឆ្នាំ២០១៣ និងលើកទិសដៅផែនការការងារឆ្នាំ២០១៤ ដើម្បីធ្វើការបូកសរុបលទ្ធផល ដើម្បីស្នើសុំសេចក្ដីសម្រេចរបស់អង្គសន្និបាត
- ធ្វើការចងក្រង បោះពុម្ពឯកសារទាំងឡាយតាមតម្រូវការរបស់អង្គសន្និបាត
- ចែកចាយឯកសារជូនគណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកាអង្គសន្និបាត
- បំពេញភារកិច្ចផ្សេងទៀតដែលគណៈកម្មការលេខាធិការដ្ឋានប្រគល់ជូន ។

**ប្រការ៤ ៖**

ត្រូវបានបង្កើតក្រុមការងារពីធីការ ជាជំនួយការអនុគណៈកម្មការលេខាធិការដ្ឋានដែលមានសមាសភាពដូចខាងក្រោម ៖

១- លោក កែវ កាន់ថរ: ប្រធាននា. សហប្រតិបត្តិការអន្តរជាតិ ប្រធាន

២- លោក រួន ទូនោរ៉ា អនុប្រធាននា. រដ្ឋបាលទូទៅ អនុប្រធាន

៣- លោក ឃួយ ញឹល អនុប្រធាននា. បុគ្គលិក សមាជិក

៤- លោក ឥន ស៊ីខុត្ដា អនុប្រធាននា. បុគ្គលិក សមាជិក

៥- លោក អ៊ិន សុខា អនុប្រធាននា. សហប្រតិបត្តិការអន្តរជាតិ សមាជិក

៦- កញ្ញា ម៉ង សុគន្ធនីកា នាយិការងសាលាបណ្ដុះបណ្ដាល សមាជិកា

៧- កញ្ញា ជា ណារិន ប្រធានការិយាល័យ សមាជិកា

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំពិធីការ បដិសណ្ឋារកិច្ច និងចាត់ចែងកម្មវិធីក្នុងអង្គសន្និបាត

- រៀបចំហុង ពិព័រណ៍ គ្រឿងបំពងសំឡេង បទភ្លេងជាតិ ថតរូបឯកសារ រៀបចំតាក តុ កៅអីសម្រាប់គណៈអធិបតី និងសមាជិក សមាជិកាអង្គសន្និបាត
- រៀបចំលិខិតអញ្ជើញ និងបញ្ជូនលិខិតអញ្ជើញជូនដល់គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងមន្ត្រីរាជការដែលត្រូវចូលរួម ។

**ប្រការ៥ ៖**

- រាល់ការចំណាយរបស់អនុគណៈកម្មការនីមួយៗ ត្រូវធ្វើគម្រោងចំណាយលម្អិត ដើម្បីស្នើសុំសេចក្ដីសម្រេចពីប្រធានគណៈកម្មការកណ្ដាល
- អនុគណៈកម្មការ និងក្រុមការងារនីមួយៗអាចប្រើប្រាស់មន្ត្រីជំនាញ ក្នុងអង្គភាពរបស់ខ្លួនជាជំនួយការដោយត្រូវរៀបចំបញ្ជីឈ្មោះមន្ត្រីទាំងនោះដើម្បីសេចក្ដីសម្រេចពីប្រធានគណៈកម្មការកណ្ដាល ។

**ប្រការ៦ ៖**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គ្រប់ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋមន្ត្រី

ភឿង សកុណា

**ចម្លងជូន ៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-ក្រសួងសុខាភិបាល
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-ដូចប្រការ៦ និងសាមីខ្លួន
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ